ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សារណៈយោគយល់គ្នា

# ស្តីពី

# *"យន្តការចែករំលែកទិន្នន័យព័ត៌មានទាក់ទងនឹងថបនីយជីវមណ្ឌលបឹងទន្លេសាប"*

ក្នុងចំណោម

## ស្ថាប័នពាក់ព័ន្ធសំខាន់ៗ

ខែកញ្ញា ឆ្នាំ២០០៦

Prepared by TSBR-ED

# អនុស្សារណៈយោគយល់គ្នា

ដោយយល់ឃើញថា

បឹង**ទន្លេសាបជាបឹងទឹកសាបដែលធំជាងគេក្នុងតំបន់អាស៊ីអាគ្នេយ៍** ជាកន្លែងដែលមានតម្លៃបរិស្ថានរួម និងជាកន្លែងស្តុកទឹកសម្រាប់ចែកចាយក្នុងរដូវប្រាំង ជានិយតករទឹកជំនន់ និងរក្សាព្រៃលិចទឹកច្រើនជាងគេក្នុងតំបន់ដីសណ្តទន្លេមេគង្គ។ ទីជំរាលនៃបឹងទន្លេសាប ឬអាងទន្លេសាបមានផ្ទៃដី ៨0.000គម[២] ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានវិសាលភាពលាតសន្ធឹងលើផ្ទៃដីសរុបរហូតដល់ ៤៤% នៃផ្ទៃប្រទេស ដោយគ្របដណ្តប់ផ្នែកខ្លះនៃខេត្ត ៩ ក្នុងចំណោមខេត្ត-ក្រុងទាំង ២៤ និងជាកន្លែងស្នាក់អាស្រ័យសម្រាប់ប្រជាជនកម្ពុជា ចំនួន ៣២% ឬស្មើនឹង ៣,៦ លាន នាក់។

**ផលិតផលត្រីនៃបឹងទន្លេសាបផ្តល់ជីវជាតិប្រូតេអ៊ីនជាង ៧0% នៃជីវជាតិប្រូតេអ៊ីននៃសាច់សត្វសម្រាប់ប្រជាជនកម្ពុជា** ទោះជាដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី តាមរយៈការផ្តល់ជាជំរកពងកូន បង្កកំណើត ឬកន្លែងផ្តល់ចំណីសម្រាប់ត្រីដែលធ្វើដំណើរជាបន្តទៅទន្លេមេគង្គ។

បឹង**ទន្លេសាបជាប្រភពទ្រទ្រង់ជីវភាពរស់នៅ និងមិនអាចជំនួស ឬខ្វះបាន សម្រាប់ប្រជាជនជាង ២លាននាក់** ដែលរស់នៅជុំវិញបឹងនេះ និងដោយកំណើនប្រជាជនរហ័ស ដែលបង្កជាសម្ពាធយ៉ាងធ្ងន់ដល់ការប្រើប្រាស់ធនធាននៅបឹងទន្លេសាប។

ធនធានធម្មជាតិបឹងទន្លេសាប គឺជាប្រភពមួយដែលអាចបង្កជាវិវាទផ្សេងៗ រវាងអ្នកពាក់ព័ន្ធ ដូចជា កត្តាវិសមភាពនៃការប្រើប្រាស់សិទ្ធិ កំណើននៃសម្ពាធប្រជាជន ភាពក្រីក្រ កង្វះខាតឬអវត្តមាននៃសិទ្ធិកាន់កាប់ ភាពខុសគ្នាផ្នែកវប្បធម៌ និងសហគមន៍ជនជាតិ គួបផ្សំនឹងការធ្វើអាជីវកម្មលើធនធាន ដូចជា ការចាប់សត្វព្រៃហួសកំរិត ការកាប់ឆ្ការព្រៃលិចទឹកសម្រាប់ធ្វើកសិកម្ម និងការនេសាទដែលធ្វើឱ្យប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាបងាយខូចខាត និងចំនួនប្រជាជនដែលពុំនាក់អាស្រ័យអាចជួបនឹងហានិភ័យធំ។ ការបាត់បង់រុក្ខធម្មជាតិក្នុងតំបន់ទីជំរាលកំពុងបំផ្លិចបំផ្លាញដល់ទីជំរកដោយធ្វើឱ្យគុណភាពទឹក និងដីកាន់តែចុះឱនភាព និងមានអត្រាល្បាប់កាន់តែច្រើនឡើង។ កង្វះខាតចំណេះដឹងអំពីផលប៉ះពាល់នៃសកម្មភាពមនុស្ស កង្វះខាតអភិបាលកិច្ច និងប្រព័ន្ធគណនេយ្យភាព និងកង្វះខាតយន្តការសម្រាប់សម្របសម្រួល និងធ្វើផែនការក្នុងការគ្រប់គ្រង គឺជាឫសគល់ដែលបង្កឱ្យមានការរិចរិល។ ជាលទ្ធផលទោះបីជាបឹងទន្លេសាបមានធនធានសំបូរបែបក៏ដោយ ក៏សូចនាករភាគច្រើនបង្ហាញថា តំបន់ថបនីយជីវមណ្ឌលបឹងទន្លេសាប មានប្រជាជនក្រីក្រច្រើនជាងគេក្នុងចំណោមតួលេខនៅទូទាំងប្រទេស។ ព្រះរាជាណាចក្រកម្ពុជានឹងជួបប្រទះវិបត្តិបរិស្ថាន បើប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាបមានការបាត់បង់ជាបន្តបន្ទាប់។

តំរូវការចាំបាច់ក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព និងការពិចារណា ដើម្បីធានាដល់និរន្តរភាពបរិស្ថានក្នុងអាងទន្លេសាប។

តំរូវការឱ្យមានការចូលរួម និងសហការគ្នា ដើម្បីដោះស្រាយវិវាទដោយក្រុមផ្សេងៗ និងស្ថាប័នពាក់ព័ន្ធនានាដែលទទួលផលពីអាងទន្លេសាប ។

តំរូវការចាំបាច់ក្នុងការរក្សាឱ្យបាននូវតុល្យភាពនៃសេចក្តីត្រូវការ និងការថែរក្សាជីវចម្រុះ និងធនធានធម្មជាតិ សំដៅធានាជីវភាពរស់នៅរបស់ប្រជាជនឱ្យបានកាន់តែប្រសើរ ។

តំរូវការបន្ទាន់ និងជាកាតព្វកិច្ច ក្នុងការបង្កើត ការថែរក្សា និងការចែកចាយទិន្នន័យបច្ចុប្បន្នភាព និងអាចជឿទុកចិត្តបានក្នុងគ្រប់វិស័យបរិស្ថាន សំដៅជួយសម្រួលដល់ការធ្វើសេចក្តីសម្រេច ការរៀបចំ ការណែនាំ ការធ្វើផែនការ ការសម្របសម្រួល ការគ្រប់គ្រង និងអភិវឌ្ឍន៍អាងទន្លេសាបឱ្យកាន់តែប្រសើរឡើង និង

យោងតាមព្រះរាជក្រឹត្យស្តីពីការបង្កើត ***ថបនីយជីវមណ្ឌលបឹងទន្លេសាប*** មានមុខងារសំខាន់បី ដែលត្រូវអនុវត្តឱ្យបានសម្រេច ដូចជា ៈ

ក) **មុខងារអភិរក្ស** ៈ អភិរក្សជីវចម្រុះ ទេសភាព សណ្ឋានដី និងប្រព័ន្ធអេកូឡូស៊ី រួមទាំងធនធានសេនេទិចប្រភេទរុក្ខជាតិ មច្ឆជាតិ និងសត្វ ព្រមទាំងស្តារឡើងវិញនូវបរិស្ថាន និងទីជម្រកនៃជីវចម្រុះ ។

ខ) **មុខងារអភិវឌ្ឍន៍** ៈ ទ្រទ្រង់ឱ្យមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពលើប្រព័ន្ធអេកូឡូស៊ី បរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

គ) **មុខងារផ្គត់ផ្គង់** ៈ ទ្រទ្រង់សកម្មភាពផ្សេងៗ រួមមានការអនុវត្តន៍គម្រោងបង្ហាញ ការអប់រំ បណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវ និងការអង្កេតតាមដាន ការប្រែប្រួលបរិស្ថាន ដែលទាក់ទងនឹងការ អភិវឌ្ឍន៍ដោយនិរន្តរភាព ការអភិរក្ស នៅក្នុងកម្រិតមូលដ្ឋាន កម្រិតជាតិ និងអន្តរជាតិ ។

ដោយយល់ឃើញថា ការបង្កើត **គណៈកម្មាធិការសម្របសម្រួលអាងទន្លេសាប** នៅក្នុងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា តាមរយៈលេខាធិការដ្ឋាន នឹងជួយដល់ការសម្របសម្រួល ជំរុញការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីឱ្យអ្នកពាក់ព័ន្ធទាំងអស់អាចទទួលបាននូវផលប្រយោជន៍ ។ ជាងនេះទៀត គណៈកម្មាធិការនេះចាំបាច់ត្រូវមានទិន្នន័យសម្រាប់ដំណើរការសកម្មភាពទៅតាមតួនាទីរបស់ខ្លួន ហើយតាមរយៈយន្តការចែករំលែកទិន្នន័យ នៃប្រព័ន្ធទិន្នន័យ-ព័ត៌មានបរិស្ថានរបស់ថបនីយជីវមណ្ឌលបឹងទន្លេសាប បានឯកភាពនៅក្នុង អ.ន.ស នេះ ត្រូវផ្តល់ទិន្នន័យ-ព័ត៌មានដូចដែលបានរៀបរាប់ខាងលើ ។

***ដោយយល់ឃើញថា ប្រព័ន្ធទិន្នន័យនៃអាងទន្លេសាប អាចជួយដល់ ៈ***

***គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា***ក្នុងការ ជួយ និងផ្តល់ប្រឹក្សាដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា លើរាល់បញ្ហាដែលទាក់ទងការធ្វើផែនការ និងការបង្កើតយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍ គ្រប់គ្រង និងថែរក្សាធនធានទឹក និងធនធានពាក់ព័ន្ធនានា ។ សម្របសម្រួល និងសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធផ្សេងៗ ដូចជា ស្ថាប័ន

ខ្សែបណ្តោយ អាជ្ញាធរខេត្ត-ក្រុង គណៈកម្មាធិការជាតិទន្លេមេគង្គ និងសហគមន៍អ្នកផ្តល់ជំនួយដែលធ្វើការស្រាវជ្រាវ អភិវឌ្ឍ គ្រប់គ្រង និងថែរក្សាធនធានទឹក និងធនធានពាក់ព័ន្ធនានា ។ល ។

**ក្រសួងបរិស្ថាន**ក្នុងការ លើកកំពស់កិច្ចការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលបង្កើនគុណភាពបរិស្ថាន សុខុមាលភាពសាធារណៈ វប្បធម៌ និងសេដ្ឋកិច្ចជាតិ ។ ជួយសម្រួលការអភិវឌ្ឍន៍ និងការអនុវត្តន៍គោលនយោបាយ ផែនការ និងបរិធានច្បាប់ដើម្បីលើកស្ទួយ និងធានាដល់ការប្រើប្រាស់ ការគ្រប់គ្រងធនធានធម្មជាតិក្នុងប្រទេសប្រកបដោយសនិទានភាព និងនិរន្តរភាព ។ លើកទឹកចិត្ត និងគាំទ្រដល់ការចូលរួមជាសាធារណៈក្នុងការធ្វើសេចក្តីសម្រេចដោះស្រាយបញ្ហានៃការប្រើប្រាស់ធនធានធម្មជាតិ និងបញ្ហាបរិស្ថាន ។ល ។

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**ក្នុងការ រៀបចំ និងប្រតិបត្តិគោលនយោបាយអភិវឌ្ឍន៍ក្នុងវិស័យកសិកម្ម ជលផល និងព្រៃឈើ សំដៅបង្កើនកម្រិត ជីវភាពរស់នៅរបស់ប្រជាជនឱ្យបានប្រសើរ ។ ត្រួតពិនិត្យ និងគ្រប់គ្រងធនធានធម្មជាតិ និងសម្រួលសកម្មភាពអាជីវកម្មទៅលើធនធានទាំងនេះ ដើម្បីសម្រេចទៅតាមសេចក្តីត្រូវការក្នុងស្រុក ដោយផ្តោតលើស្ថេរភាពនៃប្រព័ន្ធអេកូឡូស៊ី ។ល ។

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យ កសិកម្ម និងជនបទ** ក្នុងតួនាទីជាស្ថាប័នសម្របសម្រួលថ្នាក់ជាតិលើវិស័យកសិកម្ម និងជនបទដើម្បីបង្កើនកម្រិតជីវភាពរស់នៅ របស់ប្រជាជនកម្ពុជា និងជួយដល់កសិករក្នុងការបង្កើនផលិតភាពកសិកម្ម ធានាសន្តិសុខស្បៀង និងអាហា រូបត្ថម្ភ សំដៅជំរុញដល់ការកាត់បន្ថយភាពក្រីក្រនៅជនបទ ។

**ក្រសួងធនធានទឹក និងឧតុនិយម**ក្នុងការ គ្រប់គ្រងវិស័យធនធានទឹក និងឧតុនិយមនៅព្រះរាជាណាចក្រកម្ពុជា ធ្វើផែនការសម្រាប់អាជីវកម្ម អភិវឌ្ឍន៍ និងអភិរក្សធនធានទឹក និងឧតុនិយម ។ កំណត់គោលនយោបាយ និងអភិវឌ្ឍន៍យុទ្ធសាស្ត្រធនធានទឹកសំដៅបម្រើដល់ការធ្វើអាជីវកម្ម ការអភិវឌ្ឍន៍ និងការអភិរក្សដោយនិរន្តរភាពកម្រិតជាតិ និងកម្រិតអន្តរជាតិ ស្របតាមកម្មវិធីគោលនយោបាយនៃព្រះរាជាណាចក្រកម្ពុជា ។ ប្រមូល ចងក្រង និងប្រើប្រាស់ទិន្នន័យជលសាស្ត្រ និងឧតុនិយម ។ល ។

**ក្រសួងអភិវឌ្ឍន៍ជនបទ**ក្នុងការ សម្របសម្រួល សហប្រតិបត្តិការ អនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃគម្រោងអភិវឌ្ឍន៍ជនបទ និងកម្មវិធីនានាសំដៅស្តារ និងជួយអភិវឌ្ឍទីជនបទ តាមរយៈការជួយដល់ប្រជាជននៅជនបទ ។ ផ្តួចផ្តើមស្រាវជ្រាវដោយឯករាជ្យដើម្បីអភិវឌ្ឍទីជនបទនៃព្រះរាជាណាចក្រកម្ពុជា ។ វាយតម្លៃពិតម្រូវការ និងស្វែងរកដំណោះស្រាយដែលអាចធ្វើទៅបានសំដៅបង្កើនជាអតិបរមានូវឱកាសក្នុងការអភិវឌ្ឍន៍ទីជនបទ ។ល ។

**ក្រសួងមហាផ្ទៃ**ក្នុងការ គ្រប់គ្រងរដ្ឋបាលខេត្ត-ក្រុង និងធានាសុវត្ថិភាពប្រជាជន ។ ផ្តល់ការណែនាំលើការអនុវត្តន៍គោលនយោបាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុថ្នាក់ខេត្ត-ក្រុង ដើម្បីលើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាជន ។ ទទួលយក និងដោះស្រាយបណ្តឹងរបស់ប្រជាជន អនុលោមតាមសមត្ថកិច្ចដែលបានចែងក្នុងច្បាប់ សម្រាប់

អនុវត្តនៅថ្នាក់ខេត្ត-ក្រុង ។ល។

**ក្រសួងសាធារណការ និងដឹកជញ្ជូន**ក្នុងការ កសាង ថែទាំ ជួសជុល និងគ្រប់គ្រងរាល់ហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ សាឡាង នាវាដឹកទំនិញ អ្នកដំណើរ កំពង់ផែ ផ្លូវរថភ្លើង ផ្លូវទឹក និងព្រលានយន្តហោះ ។ ចូលរួមនិងសហប្រតិបត្តិការក្នុងការបង្កើតច្បាប់ បទបញ្ញត្តិ និងបទដ្ឋានសំណង់នានាដែលចាំបាច់ និងអនុវត្តគោលនយោបាយជាតិដែលពាក់ព័ន្ធរាល់ការងារសំណង់សាធារណៈក្នុងការអភិវឌ្ឍន៍ប្រទេស ។ល។

**ក្រសួងកិច្ចការនារី** តាមរយៈការផ្តល់អំណាចដល់ស្ត្រីក្នុងការបង្កើនលទ្ធភាពផ្នែកសេដ្ឋកិច្ច ការថែទាំសុខភាព ការសិក្សាអប់រំ កាត់បន្ថយវិសមភាពយេនឌ័រ ក្នុងគ្រួសារ និងក្នុងសង្គម និងបង្កើនការចូលរួមរបស់ស្ត្រីទៅក្នុងដំណើរការនៃការគ្រប់គ្រងធនធាន និងកិច្ចអភិវឌ្ឍន៍គ្រប់វិស័យក្នុងតំបន់។ លើកទឹកចិត្តដល់ស្ត្រីកម្ពុជាឱ្យមានការចូលរួមក្នុងការធ្វើសេចក្តីសម្រេចនានា ។ល។

**ក្រសួងទេសចរណ៍**ក្នុងការ ផ្សព្វផ្សាយធនធានធម្មជាតិ ផលិតផល និងសេវាកម្មទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា។ បង្ហាញពីស្ថានភាពសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ និងសុវត្ថិភាព ក្នុងព្រះរាជាណាចក្រកម្ពុជា។ ផ្តល់ព័ត៌មានសំខាន់ៗដល់ភ្ញៀវទេសចរ និងក្រុមហ៊ុនទេសចរណ៍នានាទូទាំងពិភពលោក។ ត្រួតពិនិត្យព័ត៌មាននិងឯកសារបោះពុម្ពស្តីពីទេសចរណ៍។ គ្រប់គ្រងសេវាទេសចរណ៍ និងជំនួញទាំងឡាយដែលទាក់ទងនឹងវិស័យទេសចរណ៍ ។ល។

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**ក្នុងការ លើកកំពស់ការរៀបចំ និងការអភិវឌ្ឍន៍ទី ក្រុងប្រជុំជន និងទីជនបទនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយថែរក្សាឱ្យបាននូវតុល្យភាព និងសណ្តាប់ធ្នាប់រវាងទីក្រុងទីរួមខេត្ត និងទីជនបទ ផ្អែកទៅតាមស្ថានភាពភូមិសាស្ត្រ និងលក្ខណៈពិសេសនៃជនបទនិមួយៗ។ ធានាដល់តម្លៃសម្បត្តិវប្បធម៌ និងធម្មជាតិ ដើម្បីការអភិវឌ្ឍន៍បេតិកភ័ណ្ឌប្រវត្តិសាស្ត្រ វិស័យសេដ្ឋកិច្ច និងទេសចរណ៍ និងការថែរក្សានូវគុណភាពបរិស្ថាន ។ល។

**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**ក្នុងការ អនុវត្តន៍គោលនយោបាយជាតិ តាមរយៈវិស័យឧស្សាហកម្ម ដើម្បីជំរុញការអភិវឌ្ឍន៍ឧស្សហកម្មកែច្នៃ សហគ្រាសឧស្សាហកម្មធុនតូច និងមធ្យម ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ តាមរយៈវិស័យរ៉ែ ដើម្បីស្វែងរុករកធនធានរ៉ែ ធ្វើអាជីវកម្មធនធានរ៉ែ និងដំណើរការកែច្នៃ-បន្សុតនិងតាមរយៈវិស័យថាមពល ដើម្បីរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យថាមពល ពិសេសផ្អែកលើប្រភពធនធានដែលមានក្នុងស្រុក សំដៅធានាការផ្គត់ផ្គង់ថាមពលអគ្គិសនីគ្រប់គ្រាន់ និងស្ថេរភាពតាមថ្លៃសមស្រប ធានាបាននូវសន្តិសុខថាមពល ព្រមទាំងរៀបចំចងក្រងឯកសារ តុល្យភាពថាមពល និងប្រព័ន្ធទិន្នន័យថាមពល ។

**ក្រសួងផែនការ** តាមរយៈការចងក្រង និងពង្រឹងទិន្នន័យស្ថិតិជាតិ ដែលផ្តល់ដោយអង្គភាពស្ថិតិនានា (ក្រសួង ខេត្ត-ក្រុង) ការប្រមូលទិន្នន័យតំបូងតាមរយៈគ្រួសារ ការធ្វើអង្កេត និងការធ្វើជំរឿន រៀបចំផែនការរយៈពេលវែង មធ្យម និងខ្លី និងកម្មវិធីជាតិ តាមរយៈការសម្របសម្រួលជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីធានាភាពស៊ីចង្វាក់គ្នាក្នុងវិស័យសេដ្ឋកិច្ចសង្គម និងក្នុងចំណោមខេត្ត-ក្រុង និងតំបន់នានាក្នុងទូទាំងប្រទេស ។ល។

**ក្រសួងសុខាភិបាល**ក្នុងការ សម្របសម្រួល សហប្រតិបត្តិការ អនុវត្តន៏ការតាមដាន និងវាយតម្លៃស្រាវជ្រាវលើកម្មវិធីនានាដែលទាក់ទងនឹងសុខភាពបរិស្ថាន ដើម្បីការពារ ថែទាំ ព្យាបាល សុខភាពប្រជាជន។ ផ្តល់លទ្ធភាពដែលអាចទទួលបាននូវសេវាសុខភាព ជាពិសេសសម្រាប់ក្រុមមនុស្សចាស់ វ័យកណ្តាល និងក្រុមងាយរងគ្រោះ ដូចជាអ្នកក្រីក្រជាដើម។ ទប់ស្កាត់ និងត្រួតពិនិត្យជម្ងឺឆ្លង ជម្ងឺរ៉ាំរ៉ៃ និងជម្ងឺមិនឆ្លង។ គ្រប់គ្រងវិបត្តិសុខភាពសាធារណៈ ផ្តល់តំហែទាំមាតា និងកុមារ ជាពិសេសយកចិត្តទុកដាក់ដល់ការសម្រាលបុត្រ និងជម្ងឺកុមារ និងធានាដល់ការប្រើប្រាស់ប្រសិទ្ធភាពនៃព័ត៌មានស្តីពីសុខភាពសម្រាប់ធ្វើផែនការ អនុវត្តន៍ ត្រួតពិនិត្យ និងវាយតម្លៃក្នុងវិស័យសុខាភិបាល ។ល។

*ក្រសួង ស្ថាប័នជាតិ និងអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល វិស័យឯកជន និងប្រជាជនកម្ពុជា ក្នុងការសហប្រតិបត្តិការ និងសហការគ្នា ទៅតាមអណត្តិកម្មវិធីការងាររបស់ខ្លួន ដូចដែលមានចែងនៅក្នុងច្បាប់ ឬក្នុងព្រះរាជក្រឹត្យ ។*

ដោយយល់ឃើញថាប្រព័ន្ធទិន្នន័យនៃអាងទន្លេសាប អាចជួយដល់ **ម្ចាស់ជំនួយអន្តរជាតិ ទ្វេភាគី និងពហុភាគី** ក្នុងការប្រើប្រាស់ប្រាក់កម្ចី និងជំនួយឥតសំណងរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងប្រសើរបំផុត ជួយសម្រួលដល់ការបង្រួបបង្រួមការចាប់ផ្តើមរៀបចំអន្តរវិស័យ និងស្ថាប័ន ជំរុញដល់ការអនុវត្តន៏ប្រសើរបំផុត និងការរៀនសូត្រពីគ្នាទៅវិញទៅមក តាមរយៈការបង្កើនលទ្ធភាពក្នុងការទទួលបានទិន្នន័យ និងព័ត៌មានចាំបាច់ ដែលអាចទុកចិត្តបាន ត្រឹមត្រូវ និងទាន់សភាពការណ៏ សម្រាប់ធ្វើការតាមដាន និងវាយតម្លៃពីគោលបំណងនៃគម្រោង និងកម្មវិធី ទៅតាមអណត្តិការងាររបស់ស្ថាប័នរៀងខ្លួន។

ដោយយល់ឃើញថា **តាមរយៈ អនុស្សារណៈយោគយល់គ្នានេះ គ្រប់អ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់ដែលធ្វើការក្នុងអាងទន្លេសាប គួរតែមានកម្មវត្ថុ និងផលប្រយោជន៏រួម** យើង ក្នុងចំណោមស្ថាប័នពាក់ព័ន្ធសំខាន់ៗ ("**ស្ថាប័ន**") ដែលជាហត្ថលេខីលើអនុស្សារណៈយោគយល់គ្នានេះ ("**អ.ន.ស**") បានឯកភាពគ្នាដូចតទៅ :

# ប្រការ ១

## គោលបំណង

១. គោលបំណងរួមរបស់ **អ.ន.ស** សំដៅផ្តល់ និងគាំទ្រដល់ការផ្លាស់ប្តូរ និងចែករំលែកទិន្នន័យ-ព័ត៌មាន ក្នុងចំណោម **ស្ថាប័ន** ដែលជាហត្ថលេខីខាងក្រោម ក្នុងន័យ :

ក) ជំរុញ លើកកំពស់ និងជួយសម្រួល**ដល់ប្រជាជនក្រីក្រ ធ្វើឱ្យកំណើនសេដ្ឋកិច្ចមានចីរភាព និងបង្កើនឱកាសសម្រាប់ធ្វើឱ្យជីវភាពរស់នៅបានកាន់តែប្រសើរ ព្រមទាំងបង្កើនសក្តានុភាពក្នុងការរកចំណូលសម្រាប់ប្រជាជនដែលរស់នៅ**ក្នុងតំបន់បឹងទន្លេសាប ។

ខ) លើកកំពស់ និងជួយសម្រួលដល់**ការប្រើប្រាស់ធនធានធម្មជាតិបឹងទន្លេសាបប្រកបដោយនិរន្តរភាព** (ត្រី និងប្រភពអាហារផ្សេងទៀតៗសម្រាប់មនុស្ស) **ដែលបន្តធានាដល់ការផ្គត់ផ្គង់អាហារដែលមានជីវជាតិ** សម្រាប់បម្រើដល់ប្រជាជនកម្ពុជា ។

គ) ជួយសម្រួល និង**ជំរុញលទ្ធភាពអាចប្រើប្រាស់ជាសាធារណៈបានចំពោះធនធាន និងទ្រព្យសម្បត្តិរដ្ឋទៅតាមលក្ខណៈ សមធម៌ សមូហភាព និងតម្លាភាព ។**

ឃ) ពង្រឹកប្រព័ន្ធ និង**អភិវឌ្ឍសមត្ថភាពសម្រាប់ ការសម្របសម្រួលគ្រប់គ្រងធនធានធម្មជាតិ និងធ្វើផែនការ ការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ និងការអភិរក្សជីវចម្រុះ** នៅក្នុង ឋបនីយជីវមណ្ឌលបឹងទន្លេសាប ។

ង) សម្រេចបាននូវ**ការកាត់បន្ថយអត្រានៃការបាត់បង់ជីវចម្រុះ សំដៅរួមចំណែកលប់បំបាត់ភាពក្រីក្រ និង**បម្រើឱ្យផលប្រយោជន៍រួមនៃជីវិតលើភពផែនដី ដែលជាមូលដ្ឋានសំខាន់ក្នុងការសម្រេច**ដល់គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ។**

ច) **ចែករំលែកចំណេះដឹង បទពិសោធន៍** និង**ដើម្បីពិនិត្យ**ឱកាសសម្រាប់ការចែករំលែកព័ត៌មានផ្លាស់ប្តូរ**ទិន្នន័យស្តីពីបញ្ហាបរិស្ថាន និងការអភិវឌ្ឍ** សំដៅកសាងសមត្ថភាពដល់ស្ថាប័ន ដែលជាហត្ថលេខី ។

ឆ) **បង្កើនចំណេះដឹងសាធារណៈលើបញ្ហាអភិវឌ្ឍន៍ និងបរិស្ថាន** ដើម្បីក្លាយជាអ្នកគាំទ្រ និងជាដៃគូសកម្មរបស់គម្រោង និងកម្មវិធី ។

# ប្រការ ២

## សមាសភាពស្ថាប័ន និងអាណត្តិ

១. ដើម្បីសម្រេចបានតាមគោលបំណងដូចប្រការ ១ គណៈកម្មាធិការតម្រែតម្រង់ទិសមួយនឹងត្រូវបង្កើតឡើង សំដៅលើកស្ទួយបំពេញបន្ថែមនូវសកម្មភាពដែលសមស្របសម្រាប់សម្របសម្រួល ក្នុងចំណោមស្ថាប័ននានា។ គណៈកម្មាធិការតម្រែតម្រង់ទិស ត្រូវមានសមាសភាពជាអគ្គនាយក ឬមន្ត្រីថ្នាក់ដឹកនាំដែលត្រូវបានតែងតាំងដោយក្រសួង ឬស្ថាប័ននិមួយៗ។ អ.ន.ស នេះត្រូវចុះហត្ថលេខាដោយថ្នាក់ដឹកនាំក្រសួង ឬស្ថាប័ន។

២. គណៈកម្មាធិការតម្រែតម្រង់ទិស ត្រូវផ្តល់ការណែនាំ និងយុទ្ធសាស្ត្រគាំទ្រចាំបាច់ ដើម្បីធ្វើឱ្យសម្រេចបាននូវគោលបំណងដូចប្រការ ១។ គណៈកម្មាធិការតម្រែតម្រង់ទិស ត្រូវមានសមាជិកភាពចូលរួមពីរប្រភេទ :

ក) **សមាជិកស្នូល** : រួមមាន ថ្នាក់ដឹកនាំដែលបានតែងតាំងដូចមានចែងក្នុង ប្រការ ២ ចំណុច ១ ខាងលើដែលជាហត្ថលេខី ក្នុង **អ.ន.ស** នេះ។

ខ) **សមាជិកកិត្តិយស** : រួមមាន តំណាងជាន់ខ្ពស់នៃអង្គការដែលជាម្ចាស់ជំនួយសំខាន់ៗ។

៣. ក្រសួង ឬស្ថាប័ននិមួយៗត្រូវតែងតាំង ជនបង្គោល ដែលជាថ្នាក់ដឹកនាំបច្ចេកទេស (ចាប់ពីប្រធានការិយាល័យដល់ប្រធាននាយកដ្ឋាន) ក្រោយពី **អ.ន.ស** នេះត្រូវបានចុះហត្ថលេខារួច ឬមិនឱ្យយឺតជាងកិច្ចប្រជុំលើកទី១ របស់គណៈកម្មាធិការតម្រែតម្រង់ទិសឡើយ។ ជនបង្គោលទាំងអស់រួមគ្នា បង្កើតបានជា ក្រុមការងារគ្រប់គ្រង និងផ្លាស់ប្តូរទិន្នន័យព័ត៌មាននៃថបនីយជីវមណ្ឌលបឹងទន្លេសាប (ហៅកាត់ថាក្រុមការងារ)។

៤. ក្រុមការងារ ត្រូវផ្តល់ការគាំទ្រផ្នែកប្រតិបត្តិ និងផ្នែកសម្ភារៈ ក្នុងការអនុវត្តន៍តាមការណែនាំរបស់គណៈកម្មាធិការតម្រែតម្រង់ទិស។ ក្រុមការងារ ត្រូវដើរតួនាទីដើម្បីជួយដល់គណៈកម្មាធិការតម្រែតម្រង់ទិសក្នុងការធ្វើឱ្យសម្រេចបាននូវអណត្តិរបស់ខ្លួន។ ក្រុមការងារត្រូវមានសមាជិកភាពចូលរួមពីរប្រភេទ:

ក) **សមាជិកស្នូល** : រួមមាន ថ្នាក់ដឹកនាំនាយកដ្ឋានដែលត្រូវបានតែងតាំងដោយក្រសួងនិមួយៗ ដែលជាហត្ថលេខីក្នុង **អ.ន.ស** នេះ។

ខ) **សមាជិកកិត្តិយស** : រួមមាន តំណាងជាន់ខ្ពស់នៃអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និងវិទ្យាស្ថានស្រាវជ្រាវ។

៥. ទាំងសមាជិកកិត្តិយសនៃគណៈកម្មាធិការតម្រែតម្រង់ទិស និងសមាជិកកិត្តិយសនៃក្រុមការងារ គឺជាបេក្ខភាពដែលត្រូវបានអញ្ជើញដោយគណៈកម្មាធិការតម្រែតម្រង់ទិស ។

៦. គណៈកម្មាធិការតម្រែតម្រង់ទិស គឺជាអ្នកត្រួតពិនិត្យទៅលើពាក្យស្នើសុំចូលជាសមាជិកភាពពីអង្គការក្រៅរដ្ឋាភិបាល ឬពីវិស័យឯកជន និងជាអ្នកធ្វើការសម្រេចទទួលយក ឬមិនទទួលយកបេក្ខភាពនោះ ។

៧. សំណើសុំចូលជាសមាជិកភាពពីអង្គការក្រៅរដ្ឋាភិបាល ឬពីវិស័យឯកជន ត្រូវធ្វើតាមគោលការណ៍វាយតម្លៃដោយផ្អែកលើឆន្ទៈក្នុងការចែករំលែក និងផ្តល់ព័ត៌មានដល់ប្រព័ន្ធទិន្នន័យបរិស្ថានពីសំណាក់អង្គការក្រៅរដ្ឋាភិបាល ឬវិស័យឯកជននោះ ។ គណៈកម្មាធិការតម្រែតម្រង់ទិស អាចអញ្ជើញអង្គការក្រៅរដ្ឋាភិបាល ឬវិស័យឯកជនដែលបានស្នើសុំ (ប្រសិនជាសមស្រប) ដើម្បីចូលជាសមាជិកភាពនៃក្រុមការងារ ដោយមានការបង់ថ្លៃប្រចាំឆ្នាំ ឬដោយមិនចាំបាច់បង់ថ្លៃ ។

៨. ប្រធាន ឬអនុប្រធាននៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (ក្នុងករណីប្រធានអវត្តមាន) គឺជាប្រធានគណៈកម្មាធិការតម្រែតម្រង់ទិសអចិន្ត្រៃយ៍ ។

៩. លេខាធិការរងនៃឋបនីយជីវមណ្ឌលបឹងទន្លេសាប គឺជាប្រធានអចិន្ត្រៃនៃក្រុមការងារ ។

១០. ដើម្បីសម្របសម្រួលកិច្ចការរវាងក្រុមការងារ និងគណៈកម្មាធិការតម្រែតម្រង់ទិស ឱ្យដំណើរការទៅដោយរលូន ប្រធានលេខាធិការដ្ឋាននៃឋបនីយជីវមណ្ឌលបឹងទន្លេសាប គឺជាលេខាអចិន្ត្រៃយ៍នៃគណៈកម្មាធិការតម្រែតម្រង់ទិស ។

## ប្រការ ៣

## កិច្ចសហប្រតិបត្តិការតាមវិស័យ

តាមរយៈគណៈកម្មាធិការតម្រែតម្រង់ទិស ដោយមានការគាំទ្រពីក្រុមការងារ **ស្ថាប័ន** ដែលជាហត្ថលេខីក្នុង **អ.ន.ស** នេះត្រូវ :

១. ផ្លាស់ប្តូរទិន្នន័យ-ព័ត៌មាន ស្តីពីសកម្មភាពដែលបានធ្វើដោយ **ស្ថាប័ន** និមួយៗទៅលើបញ្ហាទាក់ទងនឹងការអភិវឌ្ឍន៍ និងបរិស្ថាននៅក្នុងអាងទន្លេសាប ដូចជា ការចិញ្ចឹមជីវិត សន្តិសុខស្បៀង ចំណីអាហារ ព្រៃឈើ ជលផល ទេសចរណ៍ កសិកម្ម គមនាគមន៍ អាកាសធាតុ ការបំពុល ថាមពល ការផ្គត់ផ្គង់ទឹក ។ល។

២. កំណត់ និងលើកកំពស់សកម្មភាព ដែលអាចជួយធ្វើឱ្យសម្រេចបានតាមគោលបំណងរបស់ **អ.ន.ស** នេះ ក្នុងអណត្តិរបស់ **ស្ថាប័ន** និមួយៗ ។

៣. សម្របសម្រួលសកម្មភាពដែលសមស្របអាចធ្វើទៅបាន ឬកំណត់ និងអនុវត្តសកម្មភាពរួមគ្នា ។

៤. ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងសហប្រតិបត្តិការ ដល់សមាជិក **ស្ថាប័ន** តាមការស្នើសុំ សំដៅជួយទ្រទ្រង់ដល់សកម្មភាពដែលធ្វើឱ្យ **អ.ន.ស** អាចសម្រេចទៅតាមគោលបំណងបាន។

## ប្រការ ៤

## ទំរង់នៃកិច្ចសហប្រតិបត្តិការ

១. គណៈកម្មាធិការតម្រែតម្រង់ទិស នឹងត្រូវជួបប្រជុំយ៉ាងហោចណាស់ក្នុងមួយឆ្នាំម្តង ទៅតាមពេលវេលាណាមួយដែលសម្រេចដោយប្រធានគណៈកម្មាធិការតម្រែតម្រង់ទិស។

២. ក្រុមការងារ ត្រូវជួបប្រជុំគ្នា យ៉ាងតិចបំផុតក្នុងមួយឆ្នាំ ២ដង ទៅតាមពេលវេលាណាមួយដែលសម្រេចដោយប្រធានអចិន្ត្រៃយ៍នៃក្រុមការងារ ដើម្បីអនុវត្តរាល់កិច្ចការដែលកំណត់ដោយគណៈកម្មាធិការតម្រែតម្រង់ទិស ហើយដែលចាំបាច់សម្រាប់ធ្វើឱ្យសម្រេចទៅតាមគោលបំណងរបស់ **អ.ន.ស**។

៣. **លេខាធិការដ្ឋានជីវមណ្ឌលបឹងទន្លេសាប** (ល.ជ.ទ.ទ) ត្រូវដើរតួនាទីជាអ្នកសម្របសម្រួលចំបងនៅក្នុង **អ.ន.ស** នេះ និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស រដ្ឋបាល និងផ្គត់ផ្គង់សម្ភារៈសម្រាប់អនុវត្តអាណត្តិ **អ.ន.ស** នេះ។

## ប្រការ ៥

## សិទ្ធិ និងភាតព្វកិច្ចរបស់សមាជិកភាព

**ស្ថាប័ន**ទាំងអស់ដែលជាហត្ថលេខីក្នុង **អ.ន.ស** នេះ ត្រូវមានសិទ្ធិ និងកាតព្វកិច្ច ដូចតទៅ :

១. គ្រប់ស្ថាប័នជាសមាជិកទាំងអស់ក្នុង **អ.ន.ស** នេះ មានសិទ្ធិទទួលបានរាល់ទិន្នន័យ និងព័តិមាន ដែលមាននៅក្នុងវេបសាយនៃប្រព័ន្ធទិន្នន័យ-ព័តិមានបរិស្ថាននៃជីវមណ្ឌលបឹងទន្លេសាប។ ស្ថាប័នជាសមាជិក អាចទាញយកទិន្នន័យដោយជ្រើសរើស ឬទាំងអស់បានពី**យន្តការចែករំលែកទិន្នន័យព័តិមាន** របស់វេបសាយ។

២. ស្ថាប័ននីមួយៗជាសមាជិក មានសិទ្ធិ កែ បន្ថែម ឬលុបចោលទិន្នន័យ ដែលខ្លួនបានដាក់បញ្ចូលក្នុងវេបសាយ មានន័យថា ម្ចាស់ទិន្នន័យមានសិទ្ធិពេញលេញក្នុងការគ្រប់គ្រងទិន្នន័យទាំងឡាយដែលខ្លួនបានដាក់បញ្ចូលក្នុងវេបសាយ។ ការលុបចោល ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនមកលេខាធិការដ្ឋាននៃគណៈកម្មាធិការតម្រែតម្រង់ទិស ដើម្បីឱ្យបញ្ជីឈ្មោះទិន្នន័យអាចត្រូវបានធ្វើបច្ចុប្បន្នភាព

បានដោយត្រឹមត្រូវ

៣. គ្រប់ស្ថាប័នជាសមាជិកទាំងអស់ ត្រូវគោរពតាម ដោយធានាថារាល់ទិន្នន័យថ្មីៗដែលស្ថាប័នខ្លួនបានផលិត ត្រូវបានដាក់ និងមាននៅលើវេបសាយ ។

## ប្រការ ៦

## ទំរង់ និងប្រភេទទិន្នន័យ-ព័ត៌មានដែលត្រូវចែករំលែក

១. ជាគោលការណ៍ ការចែករំលែកទិន្នន័យ-ព័តិមាន ត្រូវធ្វើក្នុងទំរង់ជាអេឡិចត្រូនិច សម្រាប់ទ្រទ្រង់ដល់ **យន្តការចែករំលែកព័តិមាននៅតំបន់ទន្លេសាប** ដើម្បីឱ្យសមាជិក**ស្ថាប័ន** ទាំងអស់ អាចប្រើប្រាស់ទៅតាមទំរង់ដូចគ្នាដោយងាយស្រួល និងមានប្រសិទ្ធភាព ។

២. **ស្ថាប័ន** ទាំងអស់ឯកភាពក្នុងការចែករំលែកទិន្នន័យព័តិមាន ក្នុងទំរង់ជាបីប្រភេទដូចតទៅៈ

ក) **ជាអត្ថបទ** ( របាយការណ៍ សារាចរ ឯកសារណែនាំផ្សេងៗ ។ល ។)

ខ) **ជាតារាង** ( ប្រព័ន្ធទិន្នន័យ តារាង បញ្ជីក្នុងអិចសែល ។ល ។) និង

គ) **ជាផែនទី** ( ផែនទី ប្រព័ន្ធទិន្នន័យនៃរូបភាពក្នុងប្រព័ន្ធកូអរដោនេ កម្មវិធីប្រព័ន្ធព័តិមានភូមិសាស្ត្រ ។ល ។)

៣. ទិន្នន័យ-ព័តិមាន ត្រូវបានចែកចេញជាបីចំណាត់ថ្នាក់ផ្សេងគ្នាសម្រាប់បម្រើឱ្យគោលបំណងនៃការចែករំលែក ក្នុងនោះគឺ :

ក) **ព័តិមានប្រើជាសាធារណៈ** : គ្រប់ទិន្នន័យ-ព័តិមានដែលមានក្នុងចំណាត់ថ្នាក់នេះ អាចដកយកបានដោយមិនគិតថ្លៃចំពោះគ្រប់សាធារណៈជន ។ ជាទូទៅ ក្នុងចំណាត់ថ្នាក់នេះមានគ្រប់បញ្ជីស្វ័យទិន្នន័យ (បញ្ជីឈ្មោះទិន្នន័យ-ព័តិមាន) និងអាចមានព័តិមានទូទៅអំពីគម្រោង និងកម្មវិធីនៅអាងទន្លេសាប អត្ថបទ ឯកសារ ដំណឹង ព្រឹត្តិការណ៍នានា ។ល ។

ខ) **ព័តិមានប្រើមានកំរិត** : គ្រប់ទិន្នន័យ-ព័តិមានដែលមានក្នុងចំណាត់ថ្នាក់នេះ អាចដកយកបានដោយមិនគិតថ្លៃចំពោះ **ស្ថាប័ន** ដែលជាហត្ថលេខីនៃ **អ.ន.ស** ។ ចំពោះអ្នកដែលមិនមែនជាសមាជិក **អ.ន.ស** ត្រូវបង់ថ្លៃសម្រាប់ការទាញយកព័តិមានដាក់ក្នុងចំណាត់ថ្នាក់នេះ ។ ព័តិមានទាំងនេះអាចមានទិន្នន័យជាតារាងដែលប្រមូលដោយគម្រោង និងកម្មវិធីផ្សេងៗ របាយការណ៍វិវត្ត បទបញ្ជា និងសារាចររាជរដ្ឋាភិបាល ។ល ។

គ) **ព័ត៌មានបង់ថ្លៃ :** អ្នកដែលចង់ទាញយកទិន្នន័យ-ព័ត៌មានដែលឋិតក្នុងចំណាត់ថ្នាក់នេះ ត្រូវឱ្យបង់ប្រាក់ដល់ស្ថាប័ន ដែលជាអ្នកផលិតទិន្នន័យនោះ។ បញ្ជីស្ទ័យទិន្នន័យក្នុងចំណាត់ថ្នាក់នេះអាចទាញយកបានដោយមិនចាំបាច់បង់ប្រាក់ ប៉ុន្តែមិនអាចទាញយកខ្លឹមសារទិន្នន័យទាំងមូលមកប្រើប្រាស់បានឡើយលុះត្រាតែបានបង់ថ្លៃព្រមព្រៀងគ្នាមួយរវាងលេខាធិការដ្ឋានបរិស្ថានីយជីវមណ្ឌលបឹងទន្លេសាប និងស្ថាប័នដែលប្រមូល និងចងក្រងទិន្នន័យនោះជាមុនសិន។ តួយ៉ាង ទិន្នន័យនៅក្នុងចំណាត់ថ្នាក់នេះអាចទិន្នន័យជាតារាងដែលប្រមូល និងធ្វើបច្ចុប្បន្នភាពដោយនាយកដ្ឋាន មន្ទីរ ឬ ស្ថាប័នរដ្ឋាភិបាល ដែលជាផ្នែកមួយនៃសកម្មភាពជាប្រចាំរបស់ខ្លួន។ ឧទាហរណ៍ ទិន្នន័យកំពស់ទឹកភ្លៀង និងសីតុណ្ហភាពប្រមូលដោយនាយកដ្ឋានឧតុនិយម ទិន្នន័យគុណភាពទឹកប្រមូលដោយ នាយកដ្ឋានជលសាស្ត្រ ទិន្នន័យដី និងឋានលេខា ប្រមូលដោយនាយកដ្ឋានភូគ្រសាស្ត្រ ។ល។

៤. ទោះបីជាការធ្វើចំណាត់ថ្នាក់ទិន្នន័យ-ព័ត៌មាន សម្រាប់លក់ក៏ដោយ (**ព័ត៌មានបង់ថ្លៃ**) ក៏ **អ.ន.ស** ត្រូវឈរលើគោលការណ៍នៃការចែករំលែកទិន្នន័យ-ព័ត៌មានឱ្យបានទូលំទូលាយ ការប្រើប្រាស់ព័ត៌មានទាន់សភាពការណ៍ ការអភិវឌ្ឍន៍ ការកាត់បន្ថយចំណាយលើការប្រមូលទិន្នន័យ-ព័ត៌មានដែលមានស្រាប់។

៥. ទិន្នន័យ-ព័ត៌មាន និងបញ្ជីស្ទ័យទិន្នន័យ (ទិន្នន័យអំពីទិន្នន័យខ្លួនឯង) ត្រូវធ្វើការចែករំលែកក្នុងទំរង់ និងគំរូដោយមានការព្រមព្រៀងរួមគ្នាជាមុនសិន។

# ប្រការ ៧

## ហិរញ្ញកិច្ច

១. សកម្មភាពរួមដែលឋិតក្រោម **អ.ន.ស** ត្រូវអនុវត្តដោយគោរពទៅតាមលក្ខខណ្ឌដែលត្រូវមានថវិកាចូលរួមសម្រាប់បម្រើឱ្យគោលបំណងនេះ។

២. គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាត្រូវរៀបចំផែនការថវិកា និងហិរញ្ញកិច្ចសម្រាប់អនុវត្តសកម្មភាពឋិត ក្រោម **អ.ន.ស** នេះ។

៣. **ស្ថាប័ន**និមួយៗត្រូវកំណត់ពីចំណាត់ថ្នាក់ទិន្នន័យដែលខ្លួននឹងធ្វើការចែករំលែកនៅក្នុង **អ.ន.ស** នេះ មានន័យថា តើប្រភេទទិន្នន័យ-ព័ត៌មានមួយណាដែលចង់ដាក់ចូលក្នុងចំណាត់ថ្នាក់ ព័ត៌មានប្រើជាសាធារណៈ មួយណាដាក់ចូលក្នុងព័ត៌មានប្រើមានកំរិត ឬមួយណាដាក់ចូលក្នុងចំណាត់ថ្នាក់ព័ត៌មានបង់ថ្លៃ។

៤. **ស្ថាប័ន** និមួយៗអាចជ្រើសរើស ដោយការដាក់តម្លៃជាក់លាក់នៅតាមប្រភេទទិន្នន័យ-ព័ត៌មាន និមួយៗដែលខ្លួនបានចាត់ថ្នាក់នៅក្នុងប្រភេទចំណាត់ថ្នាក់ព័ត៌មានបង់ថ្លៃ ឬមានសិទ្ធិសម្រេចកំណត់តម្លៃ ក្នុងពេលលក់ទិន្នន័យ-ព័ត៌មានជាក់ស្តែងតែម្តងក៏បាន (ក្រោយពីទទួលបានសំណើតាមរយៈវេបសាយ នៃប្រព័ន្ធទិន្នន័យ-ព័ត៌មានបរិស្ថាននៃឋបនីយជីវមណ្ឌលបឹងទន្លេសាប) ដោយមានការពិភាក្សាជាមួយ អ្នកស្វែងរកព័ត៌មាន និងដោយមានការពិគ្រោះយោបល់ពីលេខាធិការដ្ឋានឋបនីយជីវមណ្ឌលបឹងទន្លេសាប។

៥. ភាគរយនៃប្រាក់ចំណូលមួយចំណែកតូចដែលទទួលបានពីការលក់ទិន្នន័យ-ព័ត៌មាន ក្នុងចំណាត់ថ្នាក់ប្រភេទទិន្នន័យ-ព័ត៌មានបង់ថ្លៃនេះ ត្រូវរក្សាទុកក្នុងហិបលេខាធិការដ្ឋានឋបនីយជីវមណ្ឌលបឹងទន្លេសាប ទៅតាមអត្រាមួយដែលមានការឯកភាពជាមុនដោយគណៈកម្មាធិការតម្រែតម្រង់ទិស។

## ប្រការ ៨

## របាយការណ៍

**ស្ថាប័ន** និមួយៗតាមរយៈជនបង្គោលរបស់ខ្លួន (សមាជិកក្រុមការងារ) ត្រូវផ្តល់របាយការណ៍វិវត្តប្រចាំឆមាសស្តីពីការអនុវត្តន៍ **អ.ន.ស** នេះ។ លេខាធិការដ្ឋានឋបនីយជីវមណ្ឌលបឹងទន្លេសាប ត្រូវចងក្រងរបាយកាណ៍វិវត្តរបស់ **ស្ថាប័ន** ទាំងនេះឱ្យទៅជារបាយណ៍វិវត្តរួមមួយ និងត្រូវដាក់ជូនទៅគណៈកម្មាធិការតម្រែតម្រង់ទិស។

## ប្រការ ៩

## ធរមានបញ្ញត្តិ ការពិនិត្យឡើងវិញ និងការបញ្ចប់ភេក្ខភាព

១. អនុស្សារណៈនេះត្រូវចូលជាធរមានក្រោយពីចុះហត្ថលេខាដោយថ្នាក់ដឹកនាំក្រសួង ឬ **ស្ថាប័ន** រួច។

២. អាចមានស្ថាប័ន ឬបេក្ខភាពផ្សេងទៀតចូលរួមបន្ថែមក្នុងអនុស្សារណៈនេះ ប្រសិនបើមានការយល់ព្រមពីគណៈកម្មាធិការតម្រែតម្រង់ទិស។ ក្រោយពីមានការទទួលយកបេក្ខភាពថ្មីរបស់ខ្លួនរួចហើយ ថ្នាក់ដឹកនាំស្ថាប័នថ្មីនោះនឹងត្រូវក្លាយជាសមាជិកគណៈកម្មាធិការតម្រែតម្រង់ទិស ដោយស្វ័យប្រវត្តិ។

៣. តាមរយៈការព្រមព្រៀងគ្នាទៅវិញទៅមក**ស្ថាប័ន** ទាំងអស់អាចពិនិត្យ និងធ្វើវិសោធនកម្ម **អ.ន.ស** នេះឡើងវិញ។

៤. **ស្ថាប័ន** និមួយៗអាចបញ្ចប់សមាជិកភាពរបស់ខ្លួនពីក្នុង **អ.ន.ស** នេះបានតាមរយៈការផ្តល់សំណេរជូនដំណឹង ១ខែ ជាមុនដល់គណៈកម្មាធិការតម្រែតម្រង់ទិស ។

ថ្ងៃទី ខែ ឆ្នាំ២០០៦

**ហត្ថលេខា**